ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា

លេខ.......................................................

# ទស្សនភាពម៉ាក្រូសេដ្ឋកិច្ច និងវិស័យធនាគារ ឆ្នាំ២០១៦ និងទស្សនវិស័យឆ្នាំ២០១៧

រៀបចំដោយ ធនាគារជាតិនៃកម្ពុជា

នៅឆ្នាំ២០១៦នេះ សេដ្ឋកិច្ចពិភពលោកបានបន្តងើបឡើងក្នុងល្បឿនយឺតនិងមិនស្មើសាច់នៅឡើយ។ នៅប្រទេសអភិវឌ្ឍន៍ សេដ្ឋកិច្ចសហរដ្ឋអាមេរិកមានកំណើនយឺតជាងការរំពឹងទុក ស្របពេលដែលការងើបឡើងនៃសេដ្ឋកិច្ចនៅតំបន់អឺរ៉ូបន្តមានភាពទន់ខ្សោយ ដោយសារភាពមិនច្បាស់លាស់ពីឥទ្ធិពលនៃការចាកចេញរបស់ប្រទេសអង់គ្លេសពីសហភាពអឺរ៉ុប (Brexit) បន្ថែមលើភាពទន់ខ្សោយដែលមានស្រាប់។ ដោយឡែកចំពោះប្រទេសជប៉ុន ថ្វីត្បិតតែសេដ្ឋកិច្ចទទួលបានកំណើនទាប ប៉ុន្តែបន្តងើបឡើងសន្សឹមៗ ដែលគាំទ្រដោយគោលនយោបាយរូបិយវត្ថុ និងសារពើពន្ធវិត្តារកម្ម។ ចំណែកឯនៅប្រទេសកំពុងងើបឡើងនិងប្រទេសកំពុងអភិវឌ្ឍន៍ កំណើនសេដ្ឋកិច្ចចិនបានបន្តថយល្បឿនសន្សឹមៗទៅរកតុល្យភាព ដែលផ្អែកកាន់តែច្រើនទៅលើការប្រើប្រាស់និងវិស័យសេវាកម្ម ខណៈដែលសេដ្ឋកិច្ចអាស៊ាន-៥ រក្សាបានសន្ទុះកំណើនរឹងមាំ ដោយសារតែការអនុវត្តគោលនយោបាយគាំទ្រតម្រូវការក្នុងស្រុក និងការកាត់បន្ថយផលប៉ះពាល់ពីខាងក្រៅ។

ស្ថិតក្នុងបរិការណ៍នេះ សេដ្ឋកិច្ចកម្ពុជាបន្តមានកំណើនគួរជាទីពេញចិត្តនៅឆ្នាំ២០១៦ ក្នុងអត្រាខ្ពស់ប្រមាណ ៧% ដែលគាំទ្រដោយកំណើនរឹងមាំនៃការនាំចេញផលិតផលសម្លៀកបំពាក់និងស្បែកជើង កំណើនក្នុងវិស័យសំណង់និងអចលនទ្រព្យ និងវិស័យទេសចរណ៍ ស្របពេលដែលវិស័យកសិកម្មបានកើនឡើងជាងមុនបន្តិច។ ទន្ទឹមនេះ សក្តានុពលសេដ្ឋកិច្ចកម្ពុជាដែលបន្តទាក់ទាញលំហូរចូលវិនិយោគផ្ទាល់បរទេស (១០,៧% នៃផ.ស.ស) គួបផ្សំនឹងភាពប្រសើរឡើងនៃឱនភាពជញ្ជីងពាណិជ្ជកម្ម (-៧,២% នៃផ.ស.ស) បានធ្វើឱ្យជញ្ជីងទូទាត់កម្ពុជាទទួលបានអតិរេក (៥,៧% នៃផ.ស.ស) ខ្ពស់ជាងឆ្នាំ ២០១៥ (៣,៧% នៃផ.ស.ស) ដែលរួមចំណែកគរពូនទុនបម្រុងអន្តរជាតិឱ្យកើនឡើង និងអាចធានាដល់ការទូទាត់ការនាំចូលទំនិញនិងសេវាបានប្រមាណ ៥ខែ។ ចំពោះស្ថានភាពថ្លៃ អត្រាអតិផរណាបានបន្តស្ថិតក្នុងកម្រិតទាបប្រមាណ ២,៩%។ មូលហេតុចម្បងដែលនាំឱ្យមានអតិផរណាគឺកំណើនថ្លៃក្រុមម្ហូបអាហារ ភោជនីយដ្ឋាន និងសម្លៀកបំពាក់ ដែលគាំទ្រដោយកំណើនតម្រូវការក្នុងស្ថានភាពដែលជីវភាពប្រជាជនមានភាពប្រសើរឡើង។ គួរកត់សម្គាល់ថាការសម្រេចបានកម្រិតទាបនៃអតិផរណានារយៈពេលកន្លងមក បានពឹងផ្អែកមួយផ្នែកលើតម្លៃប្រេងទាប រួមនឹងការអនុវត្តគោលនយោបាយសារពើពន្ធ រូបិយវត្ថុ និងប្តូរប្រាក់សមស្របទៅនឹងកំណើនសកម្មភាពសេដ្ឋកិច្ច។ ការផ្គត់ផ្គង់រូបិយវត្ថុ (M2) មានកំណើន ២១% ប្រហាក់ប្រហែលនឹងអត្រាកំណើនជាមធ្យមក្នុងរយៈពេល ៥ឆ្នាំ ចុងក្រោយ។ កំណើនរូបិយវត្ថុទូទៅបានបង្កើនភាពស៊ីជម្រៅផ្នែកហិរញ្ញវត្ថុ (M2/GDP) ដល់កម្រិត ៧៤% ធៀបនឹង ៦៧% នៅឆ្នាំមុន។ ការកើនឡើងនេះមិន


ប្រអប់សំបុត្រលេខ ២៥, ឡូត៍លេខ ២២-២៤ មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ, ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ . ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

បានដាក់សម្ពាធលើអតិផរណាទេ ពីព្រោះវិស័យធនាគារមិនបានបង្កើនការផ្តល់ឥណទានក្នុងល្បឿនលឿនជាងមុនដោយសារ សន្ទនីយភាពត្រូវបានរក្សាទុក ឆ្លើយតបនឹងការតម្រូវនៃបទប្បញ្ញត្តិអនុបាតក្របខ័ណ្ឌសន្ទនីយភាព ដែលមានកម្រិតខ្ពស់ជាមុន។

យ៉ាងណាមិញ ស្ថិតក្នុងបរិការណ៍ដែលវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុកម្ពុជាកាន់តែអភិវឌ្ឍនិងមានភាពប្រទាក់ក្រឡា ហើយដុល្លារូបនីយកម្មនៅតែមានកម្រិតខ្ពស់ (ប្រាក់បញ្ញើជារូបិយប័ណ្ណស្មើនឹង៨៣% នៃរូបិយវត្ថុទូទៅ) គោលនយោបាយរូបិយវត្ថុមិនអាចមានប្រសិទ្ធភាពពេញលេញបានទេ ជាពិសេស ក្នុងករណីដែលស្ថានភាពសេដ្ឋកិច្ចជួបនឹងការប៉ះទង្គិចជាយថាហេតុ។ ហេតុដូចនេះ ធនាគារជាតិនៃកម្ពុជាបាននិងកំពុងបន្តកិច្ចខិតខំប្រឹងប្រែងលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀលបន្ថែមលើយន្តការដែលមានស្រាប់ ដោយបានពង្រឹងការយល់ដឹងរបស់សាធារណជនអំពីសារៈសំខាន់នៃរូបិយវត្ថុជាតិ, សម្រួលការទូទាត់ជាប្រាក់រៀលឱ្យកាន់តែឆាប់រហ័សនិងចំណាយទាប, អភិវឌ្ឍឧបករណ៍និងប្រតិបត្តិការផ្តល់សន្ទនីយភាពជាប្រាក់រៀល និងបានជំរុញឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុរួមចំណែកផ្តល់ឥណទានជាប្រាក់រៀលបន្ថែមទៀត។

ទន្ទឹមនេះ វិស័យធនាគារកម្ពុជាបានបន្តរីកចម្រើនប្រកបដោយភាពរឹងមាំ និងបានរួមចំណែកគាំទ្រកំណើនសកម្មភាពសេដ្ឋកិច្ចប្រកបដោយចីរភាពនិងបរិយាប័ន្ន ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល។ ជាក់ស្តែង ទ្រព្យសកម្មប្រព័ន្ធធនាគារបានកើនឡើងដល់ ១១២,៦ ទ្រីលានរៀល (ប្រមាណ ២៧,៨ ប៊ីលានដុល្លារអាមេរិក កើន ១៧,៥%) ហើយឥណទាន និងប្រាក់បញ្ញើមានកំណើនដល់ ៧១,២ ទ្រីលានរៀល (ប្រមាណ ១៧,៦ ប៊ីលានដុល្លារអាមេរិក កើន ១៨,៣%) និង ៦២,៥ ទ្រីលានរៀល (ប្រមាណ ១៥,៥ ប៊ីលានដុល្លារអាមេរិក កើន ២០,៧%) រៀងគ្នា។ សុខភាពប្រព័ន្ធធនាគារបន្តមានភាពរឹងមាំ ដែលឆ្លុះបញ្ចាំងដោយកម្រិតខ្ពស់នៃអនុបាតសន្ទនីយភាពរបស់គ្រឹះស្ថានធនាគារ និងមីក្រូហិរញ្ញវត្ថុ (១២៨% និង ១៥២% រៀងគ្នា) កម្រិតខ្ពស់នៃអនុបាតសាធនភាព (២២,៥% និង ២១% រៀងគ្នា) និងកម្រិតទាបនៃអនុបាតឥណទានមិនដំណើរការ (៣,៥% និង ១% រៀងគ្នា)។ គួររំលេចផងដែរថា អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជាបានបន្តលើកកម្ពស់សមត្ថភាពតាមដាននិងវាយតម្លៃប្រតិបត្តិការហិរញ្ញវត្ថុជាប់ជាប្រចាំ និងបានពង្រឹងការទប់ស្កាត់ការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មបានយ៉ាងមានប្រសិទ្ធភាព។

ប្រាកដណាស់ វិស័យធនាគារនៅកម្ពុជាមានការប្រកួតប្រជែងខ្ពស់ និងបានធ្វើឱ្យអត្រាការប្រាក់ឥណទានថយចុះជាលំដាប់ ដោយចំពោះគ្រឹះស្ថានធនាគារ អត្រាការប្រាក់ឥណទានជាប្រាក់ដុល្លារអាមេរិកគិតជាមធ្យមបានថយចុះពីជាង១៧% ក្នុងមួយឆ្នាំ នៅឆ្នាំ២០០៥ មក១១,៨% នៅឆ្នាំ២០១៦ ហើយចំពោះគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អត្រានេះបានថយចុះពីប្រមាណជិត ៥០% ក្នុងមួយឆ្នាំ មក ២៨%។ ក៏ប៉ុន្តែអត្រាអត្រាការប្រាក់ឥណទាននៅតែមានកម្រិតខ្ពស់នៅឡើយ ជាពិសេសចំពោះសេវាមីក្រូហិរញ្ញវត្ថុ។ ជាទូទៅ ការកំណត់អត្រាការប្រាក់ គឺអាស្រ័យលើកម្រិតហានិភ័យដែលគ្រឹះស្ថានត្រូវប្រឈម, តម្លៃដើមទុន, និងចំណាយប្រតិបត្តិការ។ ដោយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនៅកម្ពុជា ភាគច្រើនទទួលហិរញ្ញប្បទានពីវិនិយោគិនក្នុងនិងក្រៅប្រទេសដែលមានអត្រាការប្រាក់ខ្ពស់ គួបផ្សំនឹងចំណាយប្រតិបត្តិការខ្ពស់ ជាពិសេសចំពោះឥណទានខ្នាតតូចនិងប្រតិបត្តិការឥណទាននៅជនបទ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុក៏ត្រូវកំណត់យកអត្រាការប្រាក់ឥណទានខ្ពស់ពីប្រជាពលរដ្ឋផងដែរ។ នារយៈពេលកន្លងមក ដើម្បីរួមចំណែកកាត់បន្ថយអត្រាការប្រាក់ឥណទាន ធនាគារជាតិ

នៃកម្ពុជាបានបន្តធានានូវបរិស្ថានប្រកួតប្រជែងប្រកបដោយតម្លាភាពនិងសមភាព ព្រមទាំងបានលើកទឹកចិត្តដល់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុឱ្យស្វែងរកលទ្ធភាពបន្ធូរបន្ថយអត្រាការប្រាក់ជាបន្តបន្ទាប់។ នៅឆ្នាំ២០១៦នេះ ធនាគារជាតិនៃកម្ពុជាបានដាក់ឱ្យដំណើរការនូវប្រតិបត្តិការផ្តល់សន្ទនីយភាពដោយមានការធានា (LPCO) ដែលបានផ្តល់លទ្ធភាពឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុដែលមានតម្រូវការប្រាក់រៀលក្នុងប្រតិបត្តិការទទួលបានសន្ទនីយភាពជាប្រាក់រៀលក្នុងអត្រាទាបសមរម្យ។ តាមរយៈប្រតិបត្តិការនេះ ធនាគារជាតិនៃកម្ពុជានឹងអាចមានឥទ្ធិពលលើអត្រាការប្រាក់ទីផ្សារ ក៏ដូចជារួមចំណែកបន្ទាបអត្រាការប្រាក់នេះនាពេលខាងមុខ។ យ៉ាងណាមិញ កិច្ចខិតខំប្រឹងប្រែងក្នុងការដាក់ចេញនូវវិធានថ្មីៗ ក៏ត្រូវមានការចូលរួមចំណែកពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុផងដែរ ក្នុងការផ្តល់សេវានិងផលិតផលដែលសមស្របទៅតាមតម្រូវការនិងលទ្ធភាពសងរបស់អតិថិជន។ ក្នុងន័យនេះ ការដាក់ឱ្យអនុវត្តនូវអនុស្សរណៈយោគយល់ស្តីពីសេចក្តីណែនាំការផ្តល់ឥណទានដែលបានចុះហត្ថលេខានៅឆ្នាំ២០១៦នេះនៅខេត្តព្រះសីហនុ សរបញ្ជាក់ពីការប្តេជ្ញាចិត្តរបស់សមាគមមីក្រូហិរញ្ញវត្ថុក្នុងការបញ្ចៀសបំណុលវណ្ឌករបស់អតិថិជន កាត់បន្ថយហានិភ័យឥណទាន និងរួមចំណែកកាត់បន្ថយអត្រាការប្រាក់ឥណទាន តាមរយៈការពង្រឹងគុណភាព និងភាពពេញលេញនៃការផ្តល់ព័ត៌មានឥណទានដល់ក្រុមហ៊ុនក្រេឌីតប្យូរ៉ូកម្ពុជា, ការសិក្សាកាន់តែល្អិតល្អន់លើលទ្ធភាពសងប្រាក់របស់អតិថិជន, ការលើកកម្ពស់ការប្រកួតប្រជែងប្រកបដោយវិជ្ជាជីវៈនិងក្រមសីលធម៌, និងការជំរុញការអនុវត្តគោលការណ៍គាំពារអតិថិជន។

គួរបញ្ជាក់ថា ទោះជាមានការប្រឈមយ៉ាងណា វិស័យមីក្រូហិរញ្ញវត្ថុនៅកម្ពុជាត្រូវបានទទួលស្គាល់ពីមជ្ឈដ្ឋានជាតិនិងអន្តរជាតិថាបានលើកកម្ពស់បរិយាប័ន្នហិរញ្ញវត្ថុ និងរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋកម្ពុជាជាលំដាប់។ ក្នុងឆ្នាំ២០១៦នេះ ធនាគារជាតិនៃកម្ពុជាបានរៀបចំសន្និសីទថ្នាក់ជាតិ ស្តីពីការអភិវឌ្ឍវិស័យមីក្រូហិរញ្ញវត្ថុនៅកម្ពុជា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។ សន្និសីទ នេះត្រូវបានរៀបចំឡើង ដើម្បីអបអរសាទរការរីកចម្រើននៃវិស័យមីក្រូហិរញ្ញវត្ថុក្នុងរយៈពេល ១០ឆ្នាំ ចុងក្រោយនេះ ក៏ដូចជាដើម្បីលើកកម្ពស់ការយល់ដឹងរបស់សាធារណជនអំពីការអភិវឌ្ឍវិស័យមីក្រូហិរញ្ញវត្ថុនៅកម្ពុជា និងតួនាទីដ៏សំខាន់របស់វិស័យនេះក្នុងការរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ចជាតិ និងកាត់បន្ថយភាពក្រីក្រនៅកម្ពុជា។ យោងតាមរបាយការណ៍ Doing Business 2017 របស់ធនាគារពិភពលោក ដែលបានចេញផ្សាយនៅចុងឆ្នាំ២០១៦ នេះ ប្រទេសកម្ពុជាទទួលបានចំណាត់ថ្នាក់លេខ ៧ ទូទាំងពិភពលោក ចំពោះ "ភាពងាយស្រួលក្នុងការទទួលបានឥណទាន"។

ដើម្បីបន្តលើកកម្ពស់បរិយាប័ន្នហិរញ្ញវត្ថុបន្ថែមទៀត និងកាត់បន្ថយចំណាយប្រតិបត្តិការធនាគារជាតិនៃកម្ពុជា បានយកចិត្តទុកដាក់យ៉ាងខ្លាំងទៅលើការដាក់ឱ្យប្រើប្រាស់បច្ចេកវិទ្យាថ្មីៗដែលអាចធ្វើឱ្យការផ្តល់សេវាកាន់តែមានប្រសិទ្ធភាពនិងចំណាយទាប។ ក្នុងទិសដៅនេះ ប្រព័ន្ធសម្រាប់សេវាទូទាត់រហ័ស (Fast Payment) ត្រូវបានដាក់ឱ្យប្រើប្រាស់ ដែលមិនត្រឹមតែជួយជំរុញការប្រើប្រាស់ប្រាក់រៀលប៉ុណ្ណោះទេ តែថែមទាំងផ្តល់លទ្ធភាពឱ្យប្រជាពលរដ្ឋអាចផ្ទេរប្រាក់ពីគណនីធនាគារមួយទៅគណនីធនាគារអ្នកទទួលមួយទៀតបានភ្លាមៗ។ នៅឆ្នាំ២០១៧ ខាងមុខ ធនាគារជាតិនៃកម្ពុជានឹងដាក់ឱ្យប្រើប្រាស់ប្រព័ន្ធ Central Shared Switch ដែលនឹងផ្តល់លទ្ធភាពឱ្យអតិថិជនធនាគារអាចប្រើប័ណ្ណឥណពន្ធ ដកប្រាក់ និងទូទាត់តាមទីផ្សារ (EFTPOS) ទោះជាម៉ាស៊ីននោះមិនមែន

ជាម៉ាស៊ីនរបស់គ្រឹះស្ថានធនាគារខ្លួនក៏ដោយ។ លើសពីនេះ ការទូទាត់តាមរយៈទូរស័ព្ទ និងទិញទំនិញអនឡាញ នឹងអាចធ្វើឡើងដោយងាយស្រួល មានសុវត្ថិភាព និងប្រសិទ្ធភាពខ្ពស់។ ម្យ៉ាងទៀត ធនាគារជាតិនៃកម្ពុជានឹងបន្តយុទ្ធនាការ "តោះ!និយាយពីលុយ" ឱ្យកាន់តែទូលំទូលាយ ជាពិសេសដល់សិស្សានុសិស្សថ្នាក់បឋមសិក្សានិងវិទ្យាល័យ។ យុទ្ធនាការនេះមានគោលបំណងអប់រំប្រជាជនឱ្យយល់កាន់តែច្បាស់អំពីការគ្រប់គ្រងហិរញ្ញវត្ថុគ្រួសារ ការខ្ចី និងការឱ្យខ្ចីប្រកបដោយភាពទទួលខុសត្រូវ និងយល់ដឹងអំពីលក្ខណៈនៃការខ្ចី ដើម្បីធានានិរន្តរភាពនៃបរិយាប័ន្នហិរញ្ញវត្ថុ។

ទន្ទឹមនឹងការលើកកម្ពស់បរិយាប័ន្នហិរញ្ញវត្ថុ ធនាគារជាតិនៃកម្ពុជាបានយកចិត្តទុកដាក់ជាប្រចាំលើការពង្រឹងស្ថិរភាពហិរញ្ញវត្ថុ ជាពិសេសក្នុងស្ថានភាពដែលកំណើនឥណទានបានកើនឡើងខ្ពស់ ហើយទីផ្សារហិរញ្ញវត្ថុអន្តរជាតិមានភាពមិនច្បាស់លាស់។ ក្នុងរយៈពេលប្រមាណជាងមួយទសវត្សរ៍កន្លងមក ឥណទានចំពោះវិស័យឯកជនបានកើនឡើងយ៉ាងឆាប់រហ័ស និងមានកម្រិតខ្ពស់ធៀបនឹងប្រទេសក្នុងតំបន់ ប៉ុន្តែល្បឿនកំណើនក៏មាននិន្នាការថយចុះជាលំដាប់ផងដែរ។ ជាក់ស្តែង កំណើនឥណទានបានថយចុះពី ៧៥% នៅឆ្នាំ២០០៧ មកត្រឹម ៣១% នៅឆ្នាំ២០១៤ និង ២៣% នៅឆ្នាំ២០១៦។ កំណើនឥណទាននៅកម្ពុជាក្នុងរយៈពេលមួយទសវត្សរ៍ចុងក្រោយនេះ ជាចម្បងបណ្តាលមកពី៖ i/-ការរីកចម្រើនសកម្មភាពសេដ្ឋកិច្ច, កំណើនចំណូលចំពោះប្រជាពលរដ្ឋម្នាក់ៗ (ពីប្រមាណ ៦២៨ ដល់ ១៣០០ ដុល្លារអាមេរិក) និងទស្សនវិស័យវិជ្ជមានចំពោះកំណើនសេដ្ឋកិច្ចរយៈពេលវែង (កំណើនជាមធ្យម មានអត្រាខ្ពស់ជាង ៧% និងបន្តស្ថិតក្នុងអត្រា ៧% ក្នុងរយៈពេលមធ្យម) ii/-កំណើនប្រាក់បញ្ញើរបស់អតិថិជន (កើនពី ២៧% ដល់ ៧១% នៃផ.ស.ស) និងលំហូរវិនិយោគនិងប្រាក់កម្ចីបរទេសទៅក្នុងវិស័យធនាគារ (កើនពី ៣,៣% ដល់ ៥,៩% នៃផ.ស.ស) iii/-ឥណទានបានផ្តើមចេញពីមូលដ្ឋានដែលមានទំហំតូច (ឥណទានធៀបនឹងផ.ស.សមានកម្រិត ២០% នៃផ.ស.ស នៅឆ្នាំ២០០៧ ដែលបច្ចុប្បន្នមានកម្រិត ៨៦% នៃផ.ស.ស) iv/-កំណើនប្រជាជនពេញវ័យនិងតម្រូវការសេវាហិរញ្ញវត្ថុ (អត្រាបរិយាប័ន្នហិរញ្ញវត្ថុបានកើនឡើងបីដង ដោយប្រជាជនពេញវ័យប្រមាណ ៥៩% បានប្រើប្រាស់សេវាហិរញ្ញវត្ថុក្នុងឆ្នាំ២០១៦) និង v/-កង្វះឧបករណ៍ហិរញ្ញវត្ថុនៅលើទីផ្សារហិរញ្ញវត្ថុកម្ពុជា។ ក្នុងបរិការណ៍នេះ បទប្បញ្ញត្តិម៉ាក្រូប្រុងប្រយ័ត្ននានាត្រូវបានសិក្សាយ៉ាងយកចិត្តទុកដាក់ និងបានដាក់ឱ្យអនុវត្តចំពោះគ្រឹះស្ថានធនាគារនិងមីក្រូហិរញ្ញវត្ថុ ដើម្បីកាត់បន្ថយល្បឿនកំណើនឥណទានជាលំដាប់ សំដៅរក្សាស្ថិរភាពហិរញ្ញវត្ថុ។ នៅឆ្នាំ២០១៦ នេះ ធនាគារជាតិនៃកម្ពុជាបានពង្រឹងបទប្បញ្ញត្តិលើអនុបាតក្របខ័ណ្ឌ សន្ទនីយភាព (LCR) ស្របតាមគោលការណ៍គ្រឹះបាសែល III និងការបង្កើនដើមទុនចុះបញ្ជីអប្បបរមារបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ បន្ថែមលើវិធានការដែលមានស្រាប់។ វិធានការទាំងនេះ គួបផ្សំនឹងស្ថានភាពទីផ្សារ និងការប្រុងប្រយ័ត្នរបស់គ្រឹះស្ថានបាននាំឱ្យកំណើនឥណទានថយចុះ ហើយរំពឹងថានឹងបន្តថមថយសន្សឹម (Soft landing) ដល់អត្រាប្រមាណ ២១% នៅឆ្នាំ២០១៧។ ស្ថានភាពនេះក៏នឹងតម្រូវឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុធ្វើពិពិធកម្មប្រភពចំណូលក្រៅពីចំណូលអត្រាការប្រាក់ ដើម្បីរក្សានិរន្តរភាពនៃការអភិវឌ្ឍអាជីវកម្មរបស់ខ្លួន។

ចំពោះទស្សនវិស័យនៅឆ្នាំ២០១៧ កំណើនសេដ្ឋកិច្ចពិភពលោកត្រូវបានរំពឹងថានឹងមានអត្រាខ្ពស់ជាងឆ្នាំ២០១៦ បន្តិច ដល់ ៣,៤% ទោះបីជាសេដ្ឋកិច្ចពិភពលោកអាចប្រឈមនឹងភាពមិនច្បាស់លាស់ និងហានិភ័យមួយចំនួនក៏ដោយ។ នៅក្នុងប្រទេសអភិវឌ្ឍន៍អាចកើន ១,៨% ប្រទេសកំពុងងើបឡើងនិងប្រទេសកំពុងអភិវឌ្ឍន៍អាចកើន ៤,៦% ហើយប្រទេសអាស៊ាន-៥អាចកើនបាន

៥,១%។ ដោយកម្ពុជាមានភាពបើកចំហរនិងសមាហរណកម្មខ្ពស់ទៅក្នុងតំបន់និងពិភពលោក សេដ្ឋកិច្ចកម្ពុជានឹងអាចទទួលបានភាពអំណោយផលពីការកើនឡើងនៃកំណើនសេដ្ឋកិច្ចពិភពលោក និងភាពរឹងមាំនៃកំណើនក្នុងតំបន់ ទន្ទឹមនឹងការប្រឈមហានិភ័យពីខាងក្រៅ។ ផ្អែកតាមការព្យាករ របស់ស្ថាប័នហិរញ្ញវត្ថុអន្តរជាតិធំៗ ដូចជា មូលនិធិរូបិយវត្ថុអន្តរជាតិ ធនាគារពិភពលោក និង ធនាគារអភិវឌ្ឍន៍អាស៊ី ក៏ដូចជារាជរដ្ឋាភិបាល សេដ្ឋកិច្ចកម្ពុជានឹងបន្តស្ថិតលើគន្លងនៃកំណើន រយៈពេលវែង ក្នុងអត្រាខ្ពស់ប្រមាណ ៧% នៅឆ្នាំ២០១៧ ដោយសារភាពរឹងមាំនៃវិស័យកាត់ដេរ សម្លៀកបំពាក់និងស្បែកជើង កំណើនក្នុងវិស័យសំណង់និងអចលនទ្រព្យ ជាមួយនឹងការកើន ឡើងនៃវិស័យទេសចរណ៍និងកសិកម្ម។ កំណើនសកម្មភាពសេដ្ឋកិច្ចនឹងទទួលបានអំណោយផល ពី៖ i/- ការបន្តធ្វើកំណែទម្រង់ស៊ីជម្រៅរបស់រាជរដ្ឋាភិបាលលើគ្រប់វិស័យ ii/-សក្តានុពលសេដ្ឋកិច្ច កម្ពុជាក្នុងនាមជាសមាជិកសហគមន៍សេដ្ឋកិច្ចអាស៊ាន (AEC) ដែលពង្រីកទីផ្សារកម្ពុជាឱ្យកាន់តែធំ អាចទទួលបានមូលនិធិនិងការវិនិយោគ និងបង្កើនពាណិជ្ជកម្មក្នុងតំបន់ iii/-ទីតាំងភូមិសាស្ត្រដែល ងាយស្រួលភ្ជាប់ទំនាក់ទំនងទាំងផ្លូវគោកនិងផ្លូវទឹក ក្នុងគំនិតផ្តួចផ្តើម "ខ្សែក្រវាត់មួយ-ផ្លូវមួយ" ដែលបង្កលក្ខណៈងាយស្រួយដល់ការបង្កើនការវិនិយោគនិងពាណិជ្ជកម្ម ជាមួយប្រទេសចិននិង ប្រទេសនៅតាមបណ្តោយខ្សែក្រវាត់មួយ-ផ្លូវមួយ iv/-ការបន្តទទួលបានភាពអនុគ្រោះដល់ការនាំចេញ របស់កម្ពុជា ជាពិសេសទៅសភាពអឺរ៉ុប ក្រោមរបប "អ្វីៗគ្រប់យ៉ាងលើកលែងតែអាវុធ" និងទៅ ទីផ្សារសហរដ្ឋអាមេរិក ក្រោមការលើកលែងពន្ធលើការនាំចេញផលិតផលសម្រាប់ធ្វើដំណើរ និង v/- ភាគលាភផ្នែកប្រជាសាស្ត្រ ដោយកម្ពុជាមានប្រជាជន ៦៥% មានអាយុ ក្រោម៣៥ឆ្នាំ។ ចំពោះ អត្រាអតិផរណា ត្រូវបានប៉ាន់ស្មានថានឹងកើនឡើង ក្នុងកម្រិតប្រមាណ ៣% ខ្ពស់បន្តិចធៀបនឹង ឆ្នាំ២០១៦ ដោយសារកំណើនថ្លៃប្រេងនិងអតិផរណានាំចូលពីប្រទេសជិតខាង ខណៈដែលអត្រាប្តូរ ប្រាក់នឹងបន្តមានស្ថិរភាពល្អប្រសើរ ក្នុងរង្វង់ ៤០៥០ រៀល ក្នុងមួយដុល្លារអាមេរិក។ កំណើនរូបិយវត្ថុ ទូទៅ (M2) រំពឹងថានឹងបន្តកើនឡើងប្រមាណ ១៩% ដែលគាំទ្រដោយកំណើនឥណទានចំពោះវិស័យ ឯកជន និងស្ថានភាពល្អប្រសើរនៃជញ្ជីងទូទាត់។

ទោះជាយ៉ាងនេះក្តី សក្តានុពលនៃកំណើនសេដ្ឋកិច្ចខាងលើក៏ប្រឈមនឹងហានិភ័យនៃ ការថមថយផងដែរ ដូចជា៖ i/- ផលប៉ះពាល់អវិជ្ជមានពីនិន្នាការឡើងថ្លៃនៃប្រាក់ដុល្លារអាមេរិក ចំពោះការនាំចេញនិងវិស័យទេសចរណ៍របស់កម្ពុជាដែលមានសេដ្ឋកិច្ចដុល្លារូបនីយកម្មខ្ពស់ ii/- ភាព រឹតត្បិតនៃស្ថានភាពហិរញ្ញវត្ថុអន្តរជាតិដែលអាចកាត់បន្ថយលំហូរមូលធនចូលក្នុងតំបន់ និងអាចមាន ឥទ្ធិពលបន្តមកលើកម្ពុជា តាមរយៈការបន្ថយលំហូរវិនិយោគនិងដាក់សម្ពាធលើការបង្កើនអត្រាការ ប្រាក់នៅកម្ពុជា បន្ទាប់ពីគណៈកម្មាធិការទីផ្សារចំហរបស់ធនាគារកណ្តាលអាមេរិក (FOMC) បាន សម្រេចដំឡើង អត្រាការប្រាក់គោលចំនួន ០,២៥% ដល់ ០,៧៥% នៅថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៦ នេះ iii/- ការកើនឡើងភាពប្រកួតប្រជែងនៅលើទីផ្សារនាំចេញជាមួយប្រទេសក្នុងតំបន់ និង iv/- និន្នាការ កើនឡើងនៃការអនុវត្តគោលនយោបាយពាណិជ្ជកម្មគាំពារនិយមនៅប្រទេសអភិវឌ្ឍន៍ ដែលអាច ដាក់សម្ពាធលើការនាំចេញរបស់កម្ពុជា។ ចំពោះហានិភ័យខាងក្នុង សេដ្ឋកិច្ចកម្ពុជាអាចប្រឈម នឹងហានិភ័យនៃការថយល្បឿនកំណើនក្នុងវិស័យសំណង់និងអចលនទ្រព្យ កំណើនឥណទាន យ៉ាងឆាប់រហ័សទៅវិស័យនេះ និងការថយចុះនៃឧត្តមភាពប្រកួតប្រជែងផ្នែកថ្លៃ ដោយសារកំណើន ប្រាក់បៀវត្សនិយោជិត។ ទន្ទឹមនេះ កម្ពុជាបន្តមានបញ្ហាប្រឈមរចនាសម្ព័ន្ធចម្បងៗមួយ

ចំនួន រួមមាន ៖ កម្រិតដុល្លារូបនីយកម្មខ្ពស់ តម្លៃខ្ពស់នៃថាមពលនិងការដឹកជញ្ជូន កង្វះហេដ្ឋារចនា-សម្ព័ន្ធរូបវន្ត និង កង្វះធនធានមនុស្សមានជំនាញ ជាដើម។

ដើម្បីបន្តរួមចំណែកគាំទ្រកំណើនប្រកបដោយចីរភាព ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ធនាគារជាតិនៃកម្ពុជានឹងបន្តអនុវត្តគោលនយោបាយរូបិយវត្ថុ ប្រកបដោយភាពប្រុងប្រយ័ត្ននិងទន់ភ្លន់ក្នុងគោលបំណងសម្រេចឱ្យបានការរក្សាស្ថិរភាពថ្លៃនិងតម្លៃប្រាក់រៀល សំដៅរួមចំណែកពង្រឹងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច។ ក្នុងទិសដៅនេះ ការលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀលឱ្យកាន់តែទូលំទូលាយ នៅតែជាគោលនយោបាយចម្បងមួយ ដើម្បីពង្រឹងប្រសិទ្ធភាពគោលនយោបាយរូបិយវត្ថុបន្ថែមទៀត។ ដូច្នេះ ទីផ្សារអន្តរធនាគារនឹងត្រូវបន្តអភិវឌ្ឍតាមរយៈការលើកកម្ពស់មូលបត្រអាចជួញដូរបាននិងប្រតិបត្តិការផ្តល់សន្ទនីយភាពដោយមានការធានា ហើយប្រព័ន្ធ Online Trading Platform នឹងដាក់ឱ្យប្រើប្រាស់សម្រាប់ប្រតិបត្តិការជួញដូរនិងដេញថ្លៃ ឱ្យកាន់តែមានប្រសិទ្ធភាព។ ចំណែកទីផ្សារប្តូរប្រាក់ នឹងត្រូវអភិវឌ្ឍទៅរកទីផ្សារលក់ដុំ ជាមួយនឹងការពង្រឹងការត្រួតពិនិត្យលើទីផ្សារនេះ។ ម៉្យាងទៀត ឧបករណ៍គោលនយោបាយរូបិយវត្ថុផ្សេងៗដែលផ្អែកលើយន្តការទីផ្សារក៏នឹងត្រូវសិក្សា ដើម្បីដាក់ឱ្យអនុវត្តផងដែរនាពេលអនាគត។ ទន្ទឹមនេះ ធនាគារជាតិនៃកម្ពុជានឹងបន្តពង្រឹងការអភិវឌ្ឍវិស័យធនាគារនិងហេដ្ឋារចនាសម្ព័ន្ធហិរញ្ញវត្ថុ ពាក់ព័ន្ធនានា ដើម្បីឱ្យវិស័យធនាគារកាន់តែមានសមាហរណកម្មខ្ពស់ទៅក្នុងតំបន់និងពិភពលោក, មានភាពប្រកួតប្រជែងនិងប្រសិទ្ធភាពដោយផ្អែកលើគោលការណ៍ទីផ្សារ ហើយមានលក្ខណៈពិពិធភាព និងភាពរឹងមាំ ដែលនឹងបន្តរួមចំណែករក្សាស្ថិរភាពហិរញ្ញវត្ថុ និងទ្រទ្រង់កំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព សមធម៌ និងបរិយាប័ន្ន ស្របតាមយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ឆ្នាំ២០១៦-២០២៥។ ផ្អែកលើគោលដៅទាំងនេះ ធនាគារជាតិនៃកម្ពុជានឹងបន្តធ្វើឱ្យការអនុវត្តនៃយុទ្ធសាស្ត្រនិងផែនការសកម្មភាពនានាដែលបានកំណត់ កាន់តែមានប្រសិទ្ធភាព ដោយសហការជាមួយស្ថាប័នជំនាញនានាទាំងក្នុងស្រុកនិងអន្តរជាតិ។ សមត្ថភាពត្រួតពិនិត្យ និងបទប្បញ្ញត្តិក្នុងវិស័យធនាគារនឹងបន្តពង្រឹងស្របតាមស្តង់ដារអន្តរជាតិនិងឧត្តមានុវត្តន៍អន្តរជាតិ ជាពិសេស គោលការណ៍បាសែល។ ប្រព័ន្ធចែករំលែកព័ត៌មានឥណទាននឹងត្រូវពង្រឹងនិងពង្រីកវិសាលភាព ក្នុងគោលដៅកាត់បន្ថយហានិភ័យឥណទាននិងលើកកម្ពស់តម្លាភាព ហើយយុទ្ធសាស្ត្រជាក់លាក់ទាក់ទងនឹងការអភិវឌ្ឍប្រព័ន្ធទូទាត់, ការលើកកម្ពស់បរិយាប័ន្នហិរញ្ញវត្ថុ, កិច្ចការពារអតិថិជននិងការអប់រំផ្នែកហិរញ្ញវត្ថុ នឹងត្រូវរៀបចំឡើង ដើម្បីធានាបាននូវនិរន្តរភាពនៃការអភិវឌ្ឍវិស័យធនាគារ ប្រកបដោយភាពរឹងមាំនិងបរិយាប័ន្ន។ ក្រៅពីនេះ គុណភាពស្ថិតិជាពិសេសពាក់ព័ន្ធនឹងវិស័យធនាគារ រូបិយវត្ថុ និងជញ្ជីងទូទាត់ នឹងបន្តលើកកម្ពស់ ដើម្បីធ្វើឱ្យទិន្នន័យមានភាពកាន់តែជឿជាក់បាននិងទាន់ពេលវេលា។ សមត្ថភាពស្រាវជ្រាវ, ការតាមដានស្ថានភាពម៉ាក្រូសេដ្ឋកិច្ចនិងហិរញ្ញវត្ថុទាំងក្នុងនិងក្រៅប្រទេស និងការព្យាករណ៍សូចនាករម៉ាក្រូសេដ្ឋកិច្ចសំខាន់ៗនឹងបន្តពង្រឹងក្នុងគោលដៅរួមចំណែកក្នុងការរៀបចំគោលនយោបាយផ្អែកលើលទ្ធផលវិភាគដែលមានលក្ខណៈវិទ្យាសាស្ត្រនិងការវិនិច្ឆ័យច្បាស់លាស់គ្រប់ជ្រុងជ្រោយ។

ម៉្យាងទៀត ធនាគារជាតិនៃកម្ពុជានឹងបន្តរួមចំណែកក្នុងការពង្រឹងកិច្ចសហប្រតិបត្តិការថ្នាក់តំបន់និងពិភពលោក ជាពិសេសលើការពង្រឹងបណ្តាញសុវត្ថិភាពហិរញ្ញវត្ថុនៅក្នុងតំបន់ ក្រោមពហុភាវូបនីយកម្មគំនិតផ្តួចផ្តើមឈៀងម៉ៃ (CMIM) របស់អាស៊ាន+៣, ព្រមទាំងការផ្លាស់ប្តូរបទពិសោធន៍និងព័ត៌មានក្នុងក្របខ័ណ្ឌទ្វេភាគីនិងពហុភាគី។